**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**តុលាការកំពូល**
**សភាផ្នែករដ្ឋប្បវេណី**
សំណុំរឿង រដ្ឋប្បវេណី
លេខៈ ២៣០
ចុះថ្ងៃទី ១៦ ខែសីហា ឆ្នាំ ១៩៩៩
**សាលដីកា**
លេខៈ ២០២
ចុះថ្ងៃទី ០៣ ខែតុលា ឆ្នាំ ២០០០

**តាងនាមប្រជារាស្ត្រខ្មែរ**
**តុលាការកំពូល**
បានបើកសវនាការជំនុំជំរះជាសាធារណៈ នៅថ្ងៃទី ០៣ ខែតុលា ឆ្នាំ ២០០០ ដោយមានសមាសភាពដូចតទៅៈ
១-ឯកឧត្តម ............ ជាប្រធាន
២-លោក ................ ជាចៅក្រមរបាយការណ៍
៣-លោក ............... ជាចៅក្រម
៤-លោក .................. ជាចៅក្រម
៥-លោក ................. ជាចៅក្រម
៦-លោក .............. ជាចៅក្រម
៧-លោក ................ ជាចៅក្រម
៨-លោក .................. ជាចៅក្រម
៩-លោក ................. ជាចៅក្រម

**ក្រឡាបញ្ជី**
-លោក ..................

**តំណាងមហាអយ្យការ**
-លោក ............... ជាព្រះរាជអាជ្ញា

ដើម្បីជំនុំជំរះ លើបណ្តឹងសាទុក្ខសាលដីកា៣៦៤ ចុះថ្ងៃទី២៤ខែមិថុនា ឆ្នាំ ១៩៩៩ នៃសំណុំរឿងរដ្ឋប្បវេណីលេខ ១៨ ចុះថ្ងៃទី ០២ ខែមេសា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ ។

រវាងម្ចាស់បណ្តឹងសាទុក្ខឈ្មោះ ភស -រ- ម្តាយឈ្មោះ អ៊ុត ឡូន -ស- ។

និងចុងបណ្តឹងសាទុក្ខឈ្មោះ តរម ភេទ ស្រី អាយុក ៣៥ ឆ្នាំ ជាតិខ្មែរ មុខរបរ ធ្វើឈើ មានទីលំនៅ ផ្ទះលេខ ៣៩២ ឃុំ ក្រចេះ ស្រុក ក្រចេះ ខេត្ត ក្រចេះ ។
ឪពុកឈ្មោះ តែ ខេងស៊ា -រ- ម្តាយឈ្មោះ អ៊ុក ស៊ឹមលី -រ- ប្តីឈ្មោះ ម៉ាត់ ទូច

**កម្មវត្ថុបណ្តឹងៈ** ប្តឹងទាមទារប្រាក់ ៥០.៧២៥ ដុល្លារអាមេរិក

បានឃើញបណ្តឹងសាទុក្ខលេខ ២១០ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ១៩៩៩ របស់ឈ្មោះ សួន ឌីណាសាធ តំណាងឲ្យលោក ភី លីសែ ដែលប្តឹងតវ៉ានឹងសាលដីការដ្ឋប្បវេណីលេខ ៣៦៤ ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ១៩៩៩ របស់សាលាទឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីវិនិច្ឆ័យទាំងមូល ។

បានឃើញសំណុំរឿងរដ្ឋប្បវេណីលេខ ២៣០ ចុះថ្ងៃទី១៦ ខែសីហាឆ្នាំ ១៩៩៩ របស់តុលាការកំពូល ។

បានឃើញពាក្យបណ្តឹង ចុះថ្ងៃទី ១៥ ខែកញ្ញា ឆ្នាំ១៩៩៧ របស់ឈ្មោះ តរម ,ម៉ាត់ ទូច ប្តឹងថាខ្លួន កើតទុក្ខពុំសុខចិត្តពីឈ្មោះ ភី លីសែ ដែលបានទទួលប្រាក់ខ្លួន ចំនួន ៨០.៥១៤ ដុល្លាអាមេរិក ដើម្បីធ្វើឈើឲ្យខ្លួន ហើយក្រោយមកឈ្មោះនេះបានធ្វើឈើបាន ៣៣៤ ម៉ែត្រគូប ដែលក្នុង១ម៉ែត្រគូប តម្លៃ ៩០ ដុល្លាអាមរិក សរុបស្មើនឹង ២៩.៧៩០ ដុល្លាអាមេរិក នៅសល់ប្រាក់ ៥០.៧២៥ ដុល្លាអាមេរិកទៀត ឈ្មោះ ភី លីសែ ពុំបានប្រគល់ឈើឲ្យខ្លួនឡើយ ។

ក្នុងពេលនោះខ្លួន ទៅទារឈើឈ្មោះ ភី លីសែ បានដឹកឈើយកទៅលក់ឲ្យក្រុមហ៊ុនផ្សេងទៅវិញ។ រឿងនេះខ្លួន ប្តឹងទាមទារប្រាក់របស់ខ្លួនមកវិញ ឬឈើដែលមានតម្លៃស្មើ ក៏ខ្លួនសុខចិត្តទទួលយកដែរ ។

បានឃើញដីកាសម្រេចកិច្ចការប្រញាប់លេខ១៤៧.ស៩៧ ចុះថ្ងៃទី ១៥ ខែតុលាឆ្នាំ១៩៩៧ របស់តុលាការខេត្តក្រចេះដែលបានសម្រេចៈ

១-ទទួលពាក្យបណ្តឹងកិច្ចការប្រញាប់របស់ដើមចោទ ចុះថ្ងៃទី១០ ខែតុលា ឆ្នាំ១៩៩៧ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២-បង្គាប់ឲ្យអ្នកអនុវត្តសាលក្រមនៃតុលាការខេត្តក្រចេះចុះកត់ត្រា និងឃាត់ទុកនូវទ្រព្យសម្បត្តិដូចមានខាងលើទុកជាបណ្តោះអាសន្នដើម្បីទុកជានាសំណាងឲ្យដើមចោទ

-តាមមិនឲ្យភាគីណាមួយ ឬតតិយជនដែលពាក់ពន្ធ័នឹងរឿងនេះលក់ដូរ ឬធ្វើអំណោយទានទ្រព្យសម្បត្តិទាំងនេះឲ្យទៅតតិយជនណាមួយបានឡើយ ។ ភាគីណាមួយអាចលក់ដូរ ទិញ ឬធ្វើអំណោយទានដល់តតិយជនណាម្នាក់បាន លុះណាតែតុលាការសម្រេចដល់អង្គសេចក្តី នៃរឿងជាមុនសិន ។

៣-បង្គាប់ឲ្យដើមចោទ បង់ប្រាក់គឺ ពន្ធហ្នឹង និងពន្ធចុះបញ្ជីក្តី ១៨០០រៀលប្រាក់រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល បូករួម ២០០០រៀល ។

សេចក្តីសម្រេចនេះមានអនុភាពអនុនវត្តភ្លាម ពុ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ០៥ ចុះថ្ងៃទី ២៤ ខែតុលា ឆ្នាំ១៩៩៧ របស់ឈ្មោះ ឡឹក ចំរើន ដែលប្តឹងតវ៉ានឹងដីដាកិច្ចការប្រញាប់លេខ ១៤៧ស៩៧ ចុះថ្ងៃទី១៥ ខែតុលា ឆ្នាំ១៩៩៧ របស់តុលាការខេត្តក្រចេះ ត្រង់ចំណុចទី១ នៃដីកា ដែលបានហាមឃាត់ឈើរបស់ខ្លួន ។

បានឃើញដីកាកិច្ចការប្រញាប់លេខ ១៦ពស៩៧ ចុះថ្ងៃទី ១២ ខែវិច្ឆិកា ឆ្នាំ១៩៩៧ របស់តុលាកាខេត្តក្រចេះ ដែលបានសម្រេចៈ

១-ទទួលពាក្យបណ្ដឹងតវ៉ា ចុះថ្ងៃទី ២២ខែតុលា ឆ្នាំ១៩៩៧ របស់ឈ្មោះ ឡឿក ចំរើន ទុកជា ត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-តម្កល់ដីកាកិច្ចការប្រញាប់លេខ ១៤ ចុះថ្ងៃទី ១៥ ខែតុលា ឆ្នាំ១៩៩៧ ទុកជាបានការ រៀលែងតែឈើដែលត្រូវហាមឃាត់ គឺត្រូវបង្វិលឈើចំនួន ១២៨ កំណាត់នោះឲ្យទៅតតិយជនឈ្មោះ ឡឿក ចំរើន ចាត់ចែងទៅតាមផ្លូវច្បាប់ ចាប់ពីពេលនេះតទៅ ។

៣-រឹបអូសប្រាក់ពន្ធហ្នឹង និងពន្ធចុះបញ្ជីក្តី១.៨០០ រៀល ប្រាក់រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រៀល បូករួម ២០០០ រៀល ដែលដើមចោទបានបង់ទុករួច ។

-សេចក្តីសម្រេចនេះមានអនុភាពអនុវត្តភ្លាម ៗ ។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ០១ ចុះថ្ងៃទី ០២ ខែធ្នូ ឆ្នាំ១៩៩៧ របស់ឈ្មោះ ភិន ណាគ្រី ដែលបានប្តឹងតវ៉ានឹងដីកាកិច្ចការប្រញាប់លេខ ១៦ ចុះថ្ងៃទី១២ ខែវិច្ឆិកា ឆ្នាំ១៩៩៧ របស់តុលាការខេត្តក្រចេះ ត្រង់ចំណុចនៃសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការប្រញាប់លេខ ៧៦៧ ចុះថ្ងៃទី ២២ ខែធ្នូ ឆ្នាំ១៩៩៧ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១-ទទួលបណ្តឹងឧទ្ធរណ៍របស់ឈ្មោះ ភិន ណាគ្រី តំណាងឲ្យនាង តរម ជាដើមចោទទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-បដិសេធដីសម្រេចកិច្ចការប្រញាប់លេខ ១៦ពស៩៧ ចុះថ្ងៃទី១២ខែតុលា ឆ្នាំ១៩៩៧ របស់តុលាការខេត្តក្រចេះ ដែលបានសម្រេចប្រគល់ឈើ ១២៨កំណាត់ឲ្យទៅឈ្មោះ ឡឿក ចំរើន ចោលជាអសាបង់ ។

៣-តម្កល់ដីកាសម្រេចកិច្ចការប្រញាប់លេខ ១៤ពស៩៧ ចុះថ្ងៃទី ១០ ខែតុលា ឆ្នាំ១៩៩៧ របស់តុលាការខេត្តក្រចេះ ដែលបានសម្រេចឃាត់ផ្ទះ ដី និងទូករបស់ឈ្មោះ ភី លីសែ ព្រមទាំងឈើ ១២៨កំណាត់ ទុកជាបានការ ។

៤-បង្គាប់ឲ្យលក់ឈើមូល ១២៨កំណាត់ ដែលតុលាការខេត្តក្រចេះបានឃាត់ទុករួចហើយ ហើយយកប្រាក់បានមកពីការលក់ឈើនេះទៅតម្កល់ទុកនៅតុលាការខេត្តក្រចេះ ជាបណ្តោះអាសន្ន រហូតដល់សេចក្តីសម្រេចនៃអង្គសេចក្តីចូលជាស្ថាពរ ។

៥-រឹបអូសប្រាក់ប្រដាប់ក្តីដាន់សាលឧទ្ធរណ៍ដែលដើមបណ្តឹងឧទ្ធរណ៍បានបង់រួចហើយគឺ ពន្ធហ្នឹង និងពន្ធចុះបញ្ជីក្តី ២៥៥០រៀល រង្វាន់ក្រឡាបញ្ជីកាន់ហឹបប្រាក់ ៤៥០ រៀល ។

ចំណាយលើកិច្ចប្រគល់ដីកាកោះ ៥០០០រៀល និងចំណាយលើអាជ្ញាធរតុលាការ ៥០០០រៀល សរុប ១៣០០០រៀល ។

៦-សាលដីកាកិច្ចការប្រញាប់នេះមានអានុភាពអនុវត្តភ្លាមពុទោះបីមានបណ្តឹងសាទុក្ខក៏ដោយ ។

បានឃើញសាលក្រមរដ្ឋប្បវេណីលេខ ១៣ ចុះថ្ងៃទី១០ ខែមិនាឆ្នាំ១៩៩៨ របស់តុលាការខេត្ត ក្រចេះ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី១៥ខែកញ្ញា ឆ្នាំ១៩៩៧ របស់ដើមចោទឈ្មោះ តរម ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២-ទទួលស្គាល់ការផ្ទេរសិទ្ធិរបស់លោកស្រី តរម ឲ្យទៅឈ្មោះ ភិន ណាគ្រី ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

៣-ទទួលស្គាល់កំណត់ហេតុពិភាក្សា ចុះថ្ងៃទី ១៨ខែឧសភា ឆ្នាំ១៩៩៧ រវាងដើមចោទឈ្មោះ តរម និងចុងចម្លើយឈ្មោះ ភី លីសែ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

៤-ទទួពាក្យបណ្តឹងតវ៉ាលើដីកាកិច្ចការប្រញាប់ចុះថ្ងៃទី ២២ ខែតុលាឆ្នាំ១៩៩៧ របស់តតិយជនឈ្មោះ ឡឿក ចំរើន ទុកជាត្រឹមត្រូវតាមផ្លូវច្បាប់ ។

៥-តម្កល់ដីកាសម្រេចកិច្ចការប្រញាប់លេខ ១៦ ចុះថ្ងៃទី១២ ខែវិច្ឆកា ឆ្នាំ១៩៩៧ របស់តុលាការខេត្ត ក្រចេះ ទុកជាបានការពេញទាំងមូល ។

៦-បង្គាប់ឲ្យឈ្មោះ ភី លីសែ និងប្រពន្ធឈ្មោះ នាង ស៊ីន ជាចុងចម្លើយ សង់ប្រាក់ចំនួន ៥០.៣១៤ ដុល្លាអាមេរិក (ហាសិបពាន់ បីរយដប់បួនដុល្លាអាមេរិក)ទៅឲ្យដើមចោទឈ្មោះ តរម នៅពេលសាលក្រមនេះចូលជាស្ថាពរ ។ ក្នុងករណីមិនព្រមសង់ទេនោះតុលាការនឹងរឹបអូសទ្រព្យសម្បត្តិជាចលនវត្ថុ និងអចលនវត្ថុ ដែលបានកត់ត្រាទុកក្នុងកំណត់ហេតុ ចុះថ្ងៃទី ២០ ខែតុលា ឆ្នាំ១៩៩៧ កំណត់ហេតុចុះថ្ងៃទី ១៩ ខែតុលាឆ្នាំ១៩៩៧ ដកឈើចំនួន១២៨ កំណាត់ចេញ ដើម្បីប្រកាសលក់ឡាយឡុងយកប្រាក់សងទៅដើមបំណុល ។តាមមាត្រា ២២ ,៥៧ នៃក្រឹត្យច្បាប់លេខ ៣៨ ចុះថ្ងៃទី២៨ ខែតុលាឆ្នាំ១៩៨៨ ស្តីពីកិច្ចសន្យា និងការទទួលខុសត្រូវក្រៅកិច្ចសន្យា ។

៧-បង្គាប់ឲ្យចុងចម្លើយ បង់ប្រាក់ប្រដប់ក្តីគឺ ពន្ធហ្មឹង និងពន្ធចុះបញ្ជីក្តី ១៨០០ រៀល រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០ រៀល ប្រាក់ស៊ើបអង្កេត ៥០០០រៀល បូករួម ៧០០០រៀល ។ ប្រាក់នេះបានកាត់យកពីប្រាក់ ៧០០០រៀល ដែលដើមចោទ បានបង់ទុករួច ហើយប្រាក់ស៊ើបអង្កេត ៥០០០រៀល ត្រូវបានចំណាយអស់ក្នុងពេលស៊ើបអង្កេត ។

កាលបើហួសបណ្តឹងឧទ្ធរណ៍ត្រូវបង្គាប់ឲ្យចុងចម្លើយ បង់ពន្ធសមាមាត្រ

$\frac{\text{១គុណ ១៨៣.៦៤.១០០}}{\text{១០០}}$:១.៨៣៦.៤៦១ រៀល បន្ថែមទៀតដែលត្រូវដាក់ចូលថវិការដ្ឋ ៨០ ភាគរយ

និងបានជាវង្វាន់ក្រឡាបញ្ជីទូទាំងប្រទេស ២០ ភាគរយ ពន្ធសមាមាត្រនេះត្រូវឲ្យដើមចោទ បង់ទុកជាមុនទើបបង្គាប់ឲ្យចុងចម្លើយ សងទៅដើមចោទវិញជាក្រោយ ។

៨-សាលក្រមនេះជំនុំជំរះ និងប្រកាសជាសាធារណៈចំពោះមុខដើមចោទ និងចុងចម្លើយ សម្រេចបើកផ្លូវប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់។

បានឃើញបណ្តឹងឧទ្ធរណ៍លេខ ០៤ ចុះថ្ងៃទី ១៦ ខែមីនា ឆ្នាំ១៩៩៨ របស់ឈ្មោះ ភី លីសែ ប្តឹងមិនសុខចិត្តនឹងសាលក្រមរដ្ឋប្បវេណីលេខ ១៣ ចុះថ្ងៃទី ១០ខែមីនា ឆ្នាំ១៩៩៨ របស់តុលាការខេត្តក្រចេះ លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៤០៣ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ១៩៩៨ របស់សាលឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១-ទទួលបណ្តឹងឧទ្ធរណ៍ ចុះថ្ងៃទី ១៦ ខែមីនា ឆ្នាំ១៩៩៨ របស់ឈ្មោះ ភី លីសែ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-បដិសាធសាលក្រមលេខ ១៣ ចុះថ្ងៃទី ១០ ខែមីនា ឆ្នាំ១៩៩៨ របស់តុលាការខេត្តក្រចេះ ចោលជាអាសារបង់ ។

៣-បង្គាប់ឲ្យឈ្មោះ ភី លីសែ និងប្រពន្ធឈ្មោះ នាង ស៊ីម សងប្រាក់ចំនួន ១៣.៤៨៧ ដុល្លាអាមេរិក (ដប់បីពាន់ បួនរយប៉ែតសិបប្រាំពីរដុល្លាអាមេរិក) ទៅឲ្យឈ្មោះ តរម ។ ក្នុងករណីមិនព្រមសងត្រូវរឹបអូសទ្រព្យសម្បត្តិជាចលនវត្ថុ និងអចលនវត្ថុ ដែតុលាការខេត្ត ក្រចេះបានកំណត់ហេតុ ចុះថ្ងៃទី ២០ ខែតុលា ឆ្នាំ១៩៩៧ និងកំណត់ហេតុចុះថ្ងៃទី ១៩ ខែតុលា ឆ្នាំ១៩៩៧ ដើម្បីលក់ឡាយឡុង។

៤-ឲ្យឈ្មោះ តរម បង់ប្រាក់ប្រដាប់ក្តីជាន់សាលាឧទ្ធរណ៍ ចំនួន ១៣០០០រៀល គឺពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង ២៥៥០ រៀល វង្វាន់ក្រឡាបញ្ជីកាន់ហិប្រាក់ ៤៥០រៀល ចំណាយលើការប្រគល់ដីកាកោះ ៥០០០រៀល និងអាជ្ញាធរតុលាការ៥០០០រៀល សរុប ១៣០០០ រៀល ។ បង្គាប់ឲ្យឈ្មោះ ភី លីសែ បង់ពន្ធសមាមាត្រ ១ភាគរយ លើប្រាក់ ១៣.៤៨៧ ដុល្លា កាលបើដីកានេះចូលជាស្ថាពរ ។

៥-សាលដីកានេះជំនុំជំរះជាសាធារណៈចំពោះមុខគូក្តី នៅថ្ងៃទី ១៤ ខែកក្កដា ឆ្នាំ១៩៩៨ និងប្រកាសជាសាធារណៈនៅថ្ងៃទី ១៥ខែកក្កដា ឆ្នាំ ១៩៩៨ បើកផ្លូវប្តឹងសាទុក្ខក្នុងកំណត់ច្បាប់ ។

បានឃើញបណ្តឹង សាទុក្ខលេខ ២២៧ ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ ១៩៩៨ របស់ឈ្មោះ តរម និងបណ្តឹងសាទុក្ខលេខ ៣៣១ ច៕ថ្ងៃទី ២៦ ខែសីហា ឆ្នាំ១៩៩៨ របស់ឈ្មោះ ភី លីសែ ប្តឹងមិនសុខចិត្តនឹងសាលដីកាលេខ ៤០៣ ចុះថ្ងៃទី ១៥ ខែកក្កដា ឆ្នាំ១៩៩៨ លើសេចក្តីសម្រេចទាំងមូល ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៤៤ ចុះថ្ងៃទី ០៩ ខែមីនា ឆ្នាំ១៩៩៩ របស់តុលាការកំពូល ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១-ទទួលបណ្តឹងសាទុក្ខលេខ ២២៧ ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ១៩៩៨ របស់អ្នកស្រី តរម និងបណ្តឹងសាទុក្ខលេខ ៣៣១ ចុះថ្ងៃទី ១៦ ខែកក្កដា ឆ្នាំ១៩៩៨ របស់លោក ភី លីសែ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ ។

២-ទុកជាមោឃៈសាលដីការដ្ឋប្បវេណីលេខ ៤០៣ ចុះថ្ងៃទី ១៥ ខែសីហា ឆ្នាំ១៩៩៨ របស់សាលាឧទ្ធរណ៍ ទាំងមូល ។

៣-បង្វិលសំណុំរឿងរដ្ឋប្បវេណីលេខ ២៥២ ចុះថ្ងៃទី ២៨ ខែសីហា ឆ្នាំ១៩៩៨ របស់តុលាការកំពូល ទៅសាលាឧទ្ធរណ៍ ដើម្បីជំនុំជំរះជាថ្មីឡើងវិញ ។

៤-រឹបអូសប្រាក់ប្រដាប់ក្តី ចំនួន ៣៨០០០រៀល ដែលគូភាគី បានបង់រួចហើយគឺ ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹង ចំនួន ៤០០០រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយក្នុងកិច្ចប្រគល់ដីកាកោះចំនួន ១៥០០០រៀល សរុប ១៩០០០រៀល នៅសល់ ១៩០០០រៀល ប្រគល់ឲ្យគូភាគីគឺពាក់កណ្តាលម្នាក់វិញ ។

៥-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈនៅថ្ងៃទី ០៩ ខែមីនា ឆ្នាំ១៩៩៩ ។

បានឃើញសាលដីការដ្ឋប្បវេណីលេខ ៣៦៤ ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ១៩៩៩ របស់សាលឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១-ទទួលជំនុំជំរះរឿងក្តីនេះឡើងវិញ ដោយសាលដីការដ្ឋប្បវេណីលេខ ៤៤ ចុះថ្ងៃទី ០៩ ខែមីនា ឆ្នាំ ១៩៩៩ របស់តុលាការកំពូល បង្វិលឲ្យសាលាឧទ្ធរណ៍ ជំនុំជំរះសាជាថ្មី ។

២-បដិសេធសំណូមពររបស់ចុងចម្លើយថា សុំសងជាឈើវិញនោះចោលជាអាសារបង់ដោយផ្ទុយនិងគតិច្បាប់

៣-តម្កល់សាលក្រមរដ្ឋប្បវេណីលេខ ១៣ ចុះថ្ងៃទី ១០ ខែមីនាឆ្នាំ១៩៩៨ របស់តុលាការខេត្តក្រចេះ ទុកជាបានការពេញទាំងមូល ។

៤-សាលដីកានេះជំនុំជំរៈ និងប្រកាសជាសាធារណៈ នាពេលសវនាការសម្រេចចំពោះមុខគូក្តី បើកផ្លូវប្តឹងសាទុទក្ខ ៦០ ថ្ងៃ គិតចាប់ពីពេលនេះតទៅ ។

បានឃើញបណ្តឹងសាទុក្ខលេខ ២១០ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ ១៩៩៩ របស់ឈ្មោះ សួន ឪណាសាធ តំណាងឲ្យលោក ភី លីសែ ដែលប្តឹងតវ៉ានឹងសាលដីការដ្ឋប្បវេណីលេខ ៣៦៤ ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចនៃសេចក្តីវិនិច្ឆ័យទាំងមូល ។

បានឃើញសារណាចុះថ្ងៃទី៣១ ខែសីហា ឆ្នាំ១៩៩៩ របស់លោក ភី លីសែ ។

បានឃើញសារណាតបចុះថ្ងៃទី ២២ ខែកញ្ញាឆ្នាំ១៩៩៩ របស់អ្នកស្រី តរម ។

បានស្តាប់របាយការណ៍របស់ចៅក្រមរបាយការណ៍

បានស្តាប់សេចក្តីសន្និដ្ឋាន របស់តំណាងមហាអយ្យការថាៈ

សាលដីការបស់សាលាឧទ្ធរណ៍ ដែលសម្រេចសេចក្តីមកនេះ មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់ហើយ ។

សូមក្រុមប្រឹក្សាជំនុំជំរះមេត្តា ពិនិត្យ និងសម្រេច ។

ក្រឡាបញ្ជីឡើងអានសារណារបស់លោក ភី លីសែ

បានស្តាប់ចម្លើយរបស់អ្នកស្រី តរម ជាដើមចោទ និងជាចុងបណ្តឹងសាទុក្ខបានឆ្លើយនៅពេលវនាការថាៈ លុយចំនួន ៥០.៧២៥ ដុល្លាអាមេរិក ហើយលោក ភី លីសែ នៅតុលាការថ្នាក់ក្រោមបានធានាអះអាងថា និងសងមកខ្លួនមួយខែ ១០០០រៀល ដុល្លាអាមេរិក ហើយមកហើយដល់តុលាការកំពូល បែរជាថាខ្លួនជំពាក់ប្រាក់គាត់ទៅវិញ ។ លោក ភី លីសែ បានធ្វើកិច្ចសន្យាទទួលប្រាក់ពីខ្លួន ។

-ក្រោយពីបានស្តាប់របាយការណ៍ របស់ចៅក្រមរបាយការណ៍

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

-ក្រោយពីបានស្តាប់សារណារបស់លោក ភីលីសែ និងចម្លើយរបស់អ្នកស្រី តរម

-ក្រោយពីបានពិភាក្សាត្រឹមត្រូវតាមច្បាប់ហើយ

## តុលាការកំពូល

-យល់ឃើញថាៈ បណ្តឹងសាទុក្ខលើកទី ២ លេខ ២១០ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ១៩៩៩ របស់លោក សួន ធឌីណាសាត តំណាងឲ្យលោក ភី លីសែ ប្តឹងពីសាលដីការដ្ឋប្ប វេណីលេខ ៣៦៤ ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ លើសេចក្តីសម្រេចទាំងមូល ធ្វើឡើងក្នុងកំណត់ច្បាប់ តុលាការកំពូលអាចលើករឿងនេះមកជំនុំជំរះរួមក្រុមដល់អង្គសេចក្តីបានតាមមាត្រា ១៤ នៃច្បាប់ស្តីពីការចាត់តាំង និងសកម្មភាពរបស់សាលាជំរះក្តី និងមាត្រា ២២៦ នៃច្បាប់ស្តីពីនីតិវិធីព្រហ្មទណ្ឌ ។

-យល់ឃើញថាៈ ការដែលសាលាឧទ្ធរណ៍ពុំបានពិនិត្យ និងសម្រេចឲ្យបានត្រឹមត្រូវតាមការចង្អុលបង្ហាញរបស់តុលាការកំពូលក្នុងសាលដីកាលេខ ៤៤ ចុះថ្ងៃទី ០៩ ខែមីនា ឆ្នាំ១៩៩៩ ដែលថាសាលាឧទ្ធរណ៍សម្រេចសេចក្តីលើកទី ១ ពុំបានពិចារណា អំពីសាលដីកាកិច្ចការប្រញ៉ាប់លេខ ៧៦៧ ចុះថ្ងៃទី ២២ ខែធ្នូ ឆ្នាំ ១៩៩៧ នោះជាការមិនត្រឹមត្រូវទេ ពីព្រោះថាសាលដីកាលើកទី ២ លេខ ៣៦៤ ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ១៩៩៩ របស់ខ្លួនសម្រេចតម្កល់សាលក្រមលេខខ ១៣ ចុះថ្ងៃទី ១០ ខែមីនា ឆ្នាំ ១៩៩៨ របស់តុលាការខេត្តក្រចេះទុកជាបានការពេញទាំងមូល ។ ការសម្រេចដូចច្នេះបានន័យថាសាលាឧទ្ធរណ៍បានសម្រេចតម្កល់ទុកនូវចំណុចទី៤ នឹងទី៥ នៃសាលក្រមនេះ ដែលត្រូវសាលដីកាកិច្ចការ ប្រញ៉ាប់ស្ថាបពររបស់សាលាឧទ្ធរណ៍លេខ ៧៦៧ ចុះថ្ងៃទី២២ ខែធ្នូ ឆ្នាំ១៩៩៧ ទុកជាមោឃៈរួចហើយ ។

-យល់ឃើញថាៈ ការដែលសាលាឧទ្ធរណ៍យល់ថា លោក ភី លីសែ ជំពាក់ប្រាក់ដើមចោទ ចំនួន ៥២.៨២១៧៤ ដុល្លាអាមេរិក តាមកិច្ចសន្យាចុះថ្ងៃទី ១៨ ខែឧសភា ឆ្នាំ១៩៩៧ នោះជាកិច្ចសន្យាភ័ន្តចក្រឡំ ពីព្រោះថា ឈើ ២១៨ ម៉ែត្រគូប ដែលមានតម្លៃ ២៧.៦៩៣.២៦ ដុល្លាអាមេរិក ដែលចែងក្នុងកិច្ចសន្យានេះ អ្នកស្រី តរម ពុំបានទទួលទេ អ្នកស្រីបានទទួលតែឈើចំនួន ៣៣៥,៥១៥ ម៉ែត្រគូប ដែលមានតម្លៃ ៣០.២០១ ដុល្លាអាមេរិក ប៉ុណ្ណោះ ដូចេច្នេះប្រាក់ដែលលោក ភី សែ នៅជំពាក់គឺ ៨០.៥១៥ ដុល្លាអាមេរិក ដក ៣០.២០១ ដុល្លាអាមេរិក ស្មើនឹង ៥០.៣១៤ ដុល្លាអាមេរិក ។ ចំនួននេះគឺត្រឹមត្រូវតាមការទាមទាររបស់ដើមចោទហើយ ។

-យល់ឃើញថាៈ ការដែលលោក ភី លីសែ លើកឡើងក្នុងសារណារបស់លោក ថា លោក ម៉ាត់ រុន និងអ្នកស្រី តរម ត្រូវសងប្រាក់ថ្លៃឈើចំនួន ២១៨ ម៉ែត្រគូប ស្មើនឹង ២៧.៦៩៣,២៦ ដុល្លា អាមេរិក និងប្រាក់ដែលលោកបានខាតបង់ក្នុងការប្រគល់ឲ្យលោក ឈិត ស៊ីណុង ចំនួន ២៧.១៤៨ អាមេរិក នោះជាកាពុំត្រឹមត្រូវទេ ពីព្រោះថាៈ

ក-ប្រាក់ថ្លៃឈើ២១៨ ម៉ែត្រគូប ស្មើនឹង ២៧.៦៩៣,២៦ ដុល្លាអាមេរិក គឺលោក បេ ឈុនលី បានកាត់យកឈើដែលលោក ភី លីសែ ជំពាក់អស់ហើយ ហើយអ្នកស្រី តរម ក៏ ពុំបានទូទាត់យកពីលោក បេ ឈុនលី វិញ តាមកិច្ចសន្យាចុះថ្ងៃទី ១៨ ខែឧសភា ឆ្នាំ១៩៩៧ ដែរ ពីព្រោះលោក ភី លីសែ ពុំព្រមចូលមកទូទាត់ជាមួយលោក បេ ឈុនលី តាមកិច្ចសន្យាខាងលើ ។

ខ-ប្រាក់ដែលលោក ភី លីសែ ប្រគល់ឲ្យលោក ឈិត ស៊ីណុង ចំនួន ២៧.១៤៨ ដុល្លាអាមេរិក នោះជារឿងមួយផ្សេងទៀត ដែលពុំមែនជាកតព្វកិច្ចរបស់អ្នកស្រី តរម ទេ ។

-បានឃើញថាៈ ការដែលលោក ភី លីសែ លើកឡើងថាឈើរបស់លោក ១ម៉ែត្រគូប តម្លៃ ១៦០ ដុល្លាអាមេរិក នោះពុំមានភស្តុតាងគួរឲ្យជឿបានឡើយ ។

-យល់ឃើញថាៈ លោក ភី លីសែ បានធ្វើសារណាការពាររឿងក្តីរបស់លោកជូនមកតុលាការកំពូលរួចហើយ ប៉ុន្តែតំណាងរបស់លោក ពុំបានមកចូលរួមសវនាការនេះទេ ដូច្នេះតុលាការកំពូលជំនុំជំរះរឿងនេះ កំបាំងមុខលោក ប៉ុន្តែចាត់ទុកជាចំពោះមុខ ។

-យល់ឃើញថាៈ សាលដីការដ្ឋប្បវេណីលេខ ៣៦៤ ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ ១៩៩៩ របស់សាលាឧទ្ធរណ៍ដែលបានសម្រេចតម្កល់សាលាក្រមលេខ ១៣ ចុះថ្ងៃទី១០ ខែមីនា ឆ្នាំ ១៩៩៨ របស់តុលាការខេត្តក្រចេះមានលក្ខណៈត្រឹមត្រូវហើ លើកលែងតែចំណុចទី៤ និងទី៥ នៃសាលក្រមលេខ នេះត្រូវតែទុកជាមោឃៈ ។

# ហេតុដូច្នេះ

វិនិច្ឆ័យសេចក្តី ចំពោះមុខដើមចោទ កំបាំងមុខ

ចុងចម្លើយ ប៉ុន្តែចាត់ទុកជាចំពោះមុខ

១-ទទួលបណ្តឹងសាទុក្ខលេខ ២១០ ចុះថ្ងៃទី ២៨ ខែមិថុនា ឆ្នាំ១៩៩៩ របស់ឈ្មោះ សួន ឌីណាសាធ តំណាងឲ្យលោក ភី លីសែ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ ប៉ុន្តែបដិសេធចោលដោយខុសនឹងច្បាប់ ។

២-តម្កល់សាលដីការដ្ឋប្បវេណីលេខ ៣៦៤ ចុះថ្ងៃទី ២៤ ខែមិថុនា ឆ្នាំ១៩៩៩ របស់សាលាឧទ្ធរណ៍ទុកជាបានការ លើកលែងចំណុចទី៤ នឹងទី៥ នៃសាលក្រមលេខ ១៣ ចុះថ្ងៃទី២០ ខែមិនា ឆ្នាម១៩៩៨ របស់តុលាការខេត្តក្រចេះ ដែលត្រូវទុកជាមោឃៈ ។

៣-រឹបអូសប្រាក់ប្រដាប់ក្តីចំនួន ១៩០០០រៀល ដែលលោក ភី លីសែ បានបង់រួចហើយគឺ:

-ពន្ធចុះបញ្ជីក្តី និងពន្ធហ្នឹងចំនួន ៤.០០០ រៀល ប៉ុន្តែប្រាក់នេះត្រូវកាត់ចំនួន ៨០០រៀល សម្រាប់ជារង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់

-ចំណាយលើកិច្ចប្រគល់ដីកាកោះចំនួន ១៥០០០រៀល សរុប ១៩០០០រៀល ។

-បង្គាប់ឲ្យលោក ភី លីសែ បង់ពន្ធសមាមាត្រ ១ភាគរយ លើចំនួនទឹកប្រាក់ដែលត្រូវសងទៅដើមចោទ ។

៤-សាលដីកានេះប្រកាសនាសវនាការជាសាធារណៈ នៅថ្ងៃទី០៣ ខែតុលាឆ្នាំ២០០០ ។